ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំនព្វមាស ឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងនព្វមាស ឆ្នាំ២០១៦នេះ តាមការកត់សម្គាល់ឃើញថា មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយល្អបង្គួរនៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេស។ ប្រជាកសិករបានខិតខំជំរុញការងារបង្កបង្កើនផលស្រូវរដូវវស្សាយ៉ាងសស្រាក់សស្រាំ គិតមកទល់ចុងខែកញ្ញា ឆ្នាំ២០១៦នេះ ស្ទូងនិងព្រោះសម្រេចបាន ១០២,៧៦% នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត។ ជាការកត់សម្គាល់ ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មកំពុងមាននិន្នាការកើនឡើងដែលជាបច្ច័យមួយបង្ហាញអំពីដំណើរការវិវឌ្ឍន៍នៃយន្តូបនីយកម្មកសិកម្ម។ ក្រៅពីដំណាំស្រូវ ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម ក៏មានការកើនឡើងដែរបើប្រៀបធៀបនឹងឆ្នាំមុន។ មកដល់ពេលនេះ កសិករបានប្រមូលផលស្រូវស្រាលដើមរដូវវស្សាជាបណ្តើរៗហើយៗនាថ្មីៗនេះប្រជាកសិករក៏បានជួបនូវបញ្ហាប្រឈមដោយសារការធ្លាក់ចុះតម្លៃកសិផលជាពិសេសតម្លៃស្រូវដែលបណ្តាលមកពីកត្តាជាច្រើន។ សកម្មភាពគួរកត់សម្គាល់មួយទៀត គឺមន្ត្រីជំនាញរដ្ឋបាលព្រៃឈើបានបន្តកិច្ចសហការជាមួយគណៈកម្មការជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ចុះប្រតិបត្តិការត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើនៅតាមអធិការដ្ឋានរដ្ឋបាលព្រៃឈើទាំង៤ តាមស្មារតីនៃសេចក្តីសម្រេច លេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានសម្រាប់រយៈពេល៩ខែ ឆ្នាំ២០១៦នេះ មានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវ

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៦ គិតត្រឹមថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៩៥៦ ០២៨ហ.ត ក្នុងនោះភ្ជួររាស់ដោយគោក្របីមានចំនួន ២៥៥ ៨៩៥ហ.ត និងដោយគ្រឿងយន្តមានចំនួន ២ ៧០០ ១៣៣ហ.ត តិចជាងឆ្នាំមុនចំនួន ៤៨២ ៨៨៧ហ.ត គិតក្នុងរយៈពេលដូចគ្នា
- ផ្ទៃដីសាបសម្រេចបានចំនួន ៥០ ៥៦៤ហ.ត តិចជាងឆ្នាំមុនចំនួន ១៩ ៦៥៤ហ.ត
- ផ្ទៃដីស្ទូង និងពង្រោះសម្រេចបានចំនួន ២ ៥៤៤ ៨៤០ហ.ត ស្មើនឹង ១០២,៧៦% នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុនចំនួន ៥០ ៣០៤ហ.ត និងស្រូវតាមប្រភេទរួមមាន៖



12/Oct/2016

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

-ស្រូវស្រាលចំនួន ៦១៣ ២៦៩ហ.ត លើសឆ្នាំមុនចំនួន ៥៥ ៤២៩ហ.ត

-ស្រូវកណ្ដាលចំនួន ១ ២៩៧ ៥៩៧ហ.ត លើសឆ្នាំមុនចំនួន ១០ ៩៥៤ហ.ត

-ស្រូវធ្ងន់ចំនួន ៥៦៥ ០៧៨ហ.ត លើសឆ្នាំមុនចំនួន ១ ៥២១ហ.ត

-ស្រូវចម្ការចំនួន ២៨ ១៦៧ហ.ត តិចជាងឆ្នាំមុនចំនួន ១១ ៥៧០ហ.ត

-ស្រូវឡើងទឹកចំនួន ៤០ ៧២៩ហ.ត តិចជាងឆ្នាំមុនចំនួន ៦ ០៣០ហ.ត។

○ គ្រោះខ្វះទឹកប៉ះពាល់លើផ្ទៃដីសរុបចំនួន ១៥១ ១០៨ហ.ត ក្នុងនោះមានសំណាបសរុបចំនួន ៦៦៨ហ.ត និងសន្ទូង-ពង្រោះសរុបចំនួន ១៥០ ៤៤០ហ.ត ក្នុងនោះខូចខាតចំនួន ១១ ៣៤៩ហ.ត។ ខេត្តដែលទទួលរងនូវការប៉ះពាល់មានដូចខាងក្រោម៖

| ល.រ | រាជធានី-ខេត្ត | ប៉ះពាល់ (ហ.ត) | | ខូចខាត (ហ.ត) | |
|---|---|---|---|---|---|
| | | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ |
| ១ | បន្ទាយមានជ័យ | - | ១២ ៨៩៤ | - | - |
| ២ | បាត់ដំបង | - | ៨១ ៥៣៩ | - | ១១ ៣៤៩ |
| ៣ | កំពង់ស្ពឺ | ៦០១ | ២ ៨១៨ | - | - |
| ៤ | សៀមរាប | - | ១ ២៤៩ | - | - |
| ៥ | តាកែវ | - | ១៤ ៨៩៧ | - | - |
| ៦ | ពោធិ៍សាត់ | - | ១១ ៤៦២ | - | - |
| ៧ | កំពង់ឆ្នាំង | ៦៧ | ១០៩ | - | - |
| ៨ | កណ្ដាល | - | ១ ៦១៧ | - | - |
| ៩ | ស្វាយរៀង | - | ២៣ ៤១៦ | - | - |
| ១០ | ប៉ៃលិន | - | ៥៧ | - | - |
| ១១ | កំពង់ចាម | - | ២៩២ | - | - |
| ១២ | កំពត | - | ៩០ | - | - |
| សរុប | | ៦៦៨ | ១៥០ ៤៤០ | - | ១១ ៣៤៩ |

○ ការងារប្រមូលផលស្រូវស្រាលដើមរដូវរហូតមកដល់ពេលនេះ សម្រេចបានចំនួន ២០៨ ១០១ហ.ត លើផ្ទៃដីអនុវត្តស្រូវស្រាលសរុប ៦១៣ ២៦៩ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៨៣៨ ៧២៦តោន លើសឆ្នាំមុន ៣០៣ ៥៦៩តោន។ ទិន្នផលគិតជាមធ្យម ៤,០៣០តោន/ហ.ត លើសឆ្នាំមុន ៤១២គ.ក្រ/ហ.ត។

## ១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៩១៥ ៣៤៧ហ.ត លើសឆ្នាំមុនចំនួន ៦០ ៥៣៥ហ.ត ក្នុងនោះ៖

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៨៣១ ២០៧ហ.ត ស្មើនឹង ១៣៤,៩១% នៃផែនការ ៦១៦ ១២៣ហ.ត លើសឆ្នាំមុនចំនួន ៩៣ ៣០០ហ.ត

- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៨៤ ១៤០ហ.ត ស្មើនឹង៦១,៣១% នៃផែនការ ១៣៧ ២៣៨ហ.ត តិចជាងឆ្នាំមុនចំនួន ៣២ ៧៦៥ហ.ត។

## ១.៤ ការនាំចេញអង្ករ

ការនាំចេញអង្ករកម្ពុជារយៈពេល៩ខែដើមឆ្នាំ២០១៦នេះ មានបរិមាណសរុបចំនួន ៣៦១ ៥០៥តោន ដែលមានការថយចុះចំនួន ៧ ៦០០តោន (-២,១%) តិចជាងបរិមាណនាំចេញរយៈពេល៩ខែដើមឆ្នាំ២០១៥ ដែលមានចំនួន ៣៦៩ ១០៥តោន។ ក្នុងនោះបរិមាណនាំចេញក្នុងខែកញ្ញានេះមានចំនួន ៤១ ៤២៩តោន ដែលមានការកើនឡើងចំនួន ១៤ ៤៦០តោន

(+៥៣,៦០%) ច្រើនជាងខែកញ្ញា ឆ្នាំ២០១៥ និងបាននាំចេញទៅកាន់ទិសដៅចំនួន ៦០ប្រទេស ក្នុងនោះ ប្រទេសចិនឈរលំដាប់ទី១ (៦៤ ៦៦៩តោន) ប្រទេសបារាំងឈរលំដាប់ទី២ (៥៣ ៧៨៤តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (៥១ ៣២០តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤ (២០ ៤០៥តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៥ (១៨ ៣៦៨តោន) ប្រទេសប៊ែលហ្ស៊ិកឈរលំដាប់ទី៦ (១៧ ៩៦៨តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៧ (១៦.២៩៤តោន) ប្រទេសឆែកឈរលំដាប់ទី៨ (១៥ ៩៥១តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៩ (១៣ ៥០៥តោន) និងប្រទេសអាល្លឺម៉ង់ឈរលំដាប់ទី១០ (៩ ៨៩៤តោន)។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥៨៣ | ៧៧៧ | ៥៣២ | ៣៣៨ |
| **សរុប I** | | **៥៨៣** | **៧៧៧** | **៥៣២** | **៣៣៨** |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១២ ៤០៣ | ១៥ ៨២៨ | ១០ ២៦២ | ១០ ៧០៧ |
| ២ | ក្រុមហ៊ុន ស៊ីហ្វ៉ាប់ប៊ើលីមីធីត (រតនគិរី) | ៧៩ | ២ ៤៩៨ | ៥៣ | ៨៣ |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ៩៩០ | ២ ១០១ | ៧៣៩ | ៧៧០ |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ៣ ១១០ | ៥ ៦៣៣ | ២ ៥៨៨ | ២ ៥៣៨ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣ ៩៩៧ | ៨ ៦៦១ | ២ ១១២ | ២ ១០១ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វីសសស់ (ស្នួល) | ១ ៧៤៥ | ៤ ៣៦៥ | ១ ១៦៨ | ១ ០៣៣ |
| ៧ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង រមាសហែក) | ១ ៨៨២ | ៣ ៣៩០ | ៥៣១ | ៥៤៩ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៣២៧ | ៥ ៩២៤ | ៨៨២ | ៩៥៩ |
| ៩ | ក្រុមហ៊ុនក្រេក (ខេមបូឌា) ខូអិលធីឌី | ៤ ០៣៥ | ៥ ៧៣១ | ២ ៧២៤ | ៣ ២៦៤ |
| **សរុប II** | | **៣១ ៥៦៨** | **៥៤ ១៣១** | **២១ ០៥៩** | **២២ ០០៤** |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៤ ៨៦៩ | ១៩៥ ៤៨១ | ៤ ៧៨៧ | ៤ ៤៧៩ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៨៦ ២៥១ | ១៥១ ៩២១ | ៥៩ ២៦៣ | ៥៦ ០០៤ |
| **សរុប III** | | **៩១ ១២០** | **៣៤៧ ៤០២** | **៦៤ ០៥០** | **៦០ ៤៨៣** |
| **សរុប I+II+III** | | **១២៣ ២៧១** | **៤០២ ៣១០** | **៨៥ ៦៤១** | **៨២ ៨២៥** |

- គួរកត់សម្គាល់ថា សម្រាប់ខែកញ្ញា ឆ្នាំ២០១៦នេះ តម្លៃកៅស៊ូជាមធ្យមក្នុងរង្វង់ ១ ២៤៧ដុល្លារក្នុងមួយតោន។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានចូលរួមសិក្ខាសាលាស្តីពីយន្តការដោះស្រាយបញ្ហាតម្លៃកៅស៊ូចុះថោក នៅប្រទេសស្រីលង្កា
- បានចូលរួមសិក្ខាសាលាស្តីពីការពារនិងគ្រប់គ្រងចម្រុះចំពោះជំងឺនិងកត្តាចង្រៃនៃដំណាំកសិកម្មសម្រាប់ប្រទេសអាស៊ាន នៅសាធារណរដ្ឋប្រជាមានិតចិន
- បានចុះត្រួតពិនិត្យនិងដាំដុះសកូនកៅស៊ូក្នុងឡូត៍ពិសោធន៍ក្លូននៅក្រុមហ៊ុនចម្ការកៅស៊ូ ទ្រីភាពបឹងទន្លេប្រេចនៅខេត្តព្រះវិហារ

- ធ្វើតេស្តភាគសំណាកយថាប្រភេទចំនួន ៣០ភាគសំណាក សម្រាប់ធ្វើតេស្តត្រួតពិនិត្យគុណភាពរបស់រោងចក្រកែច្នៃកៅស៊ូ

- ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី១១៥ជាមួយ IRA ដើម្បីទទួលស្គាល់ជាមន្ទីរពិសោធន៍យោងក្នុងតំបន់សម្រាប់កិច្ចសន្យាកៅស៊ូ TSR

- បានរៀបចំធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុកលើកទី៤៧ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍មូលដ្ឋាន

- បានស្រង់ទិន្នន័យដំរុគ្រប់ចម្ការពិសោធន៍ និងឧតុនិយម Sap flow និងFlux Tower

- ដាក់ជីបំប៉នកូនកៅស៊ូឆ្នាំ២០១៣-២០១៥ និងរៀបចំថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០១៦-២០១៧ និងដាំជួសកូនកៅស៊ូដែលដាំឆ្នាំ២០១៥ និងឆ្នាំ២០១៦

- វិភាគ DRC ចំនួន០២ដងលើ១៤ចម្ការពិសោធន៍ និងវិភាគស្តង់ដារ LD ចំនួន ០១ដង

- ចុះប្រមូលទិន្នន័យនិងលាបថ្នាំរំញោចចម្ការពិសោធន៍កៅស៊ូក្រែក ខេត្តត្បូងឃ្មុំ

- ចុះត្រួតពិនិត្យនិងវាយតម្លៃដោយផ្ទាល់ នៅរោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍ក្រុមហ៊ុន ស៊ីធី វ៉ាប់បើរ នៅខេត្តត្បូងឃ្មុំ

- បណ្តុះបណ្តាលនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាលាជាតិកសិកម្មព្រែកលៀប។

## ៣ ផ្នែកកសិ-ឧស្សាហកម្ម

- ចុះសិក្សាស្រាវជ្រាវសកម្មភាពចុះអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា នៅតាមបណ្តាខេត្តជាប់ព្រំដែនចំនួន ០៥ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំទ្វេភាគីរវាងកម្ពុជា-ថៃក្រោមក្របខ័ណ្ឌ ACMECS

- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Biosafety Capacity Building នៅសាធារណរដ្ឋប្រជាមានិតចិន

- បានចូលរួមសិក្ខាសាលាស្តីពី Economic Administration (Industrial Development and Promotion) នៅប្រទេសជប៉ុន

- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ២០១៦ Seminar on Agricultural Technology Innovation and Management for Countries along the Land and Maritime Silk Roads នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន

- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ២០១៦ Seminar on Modern Agricultural for Officials from Countries along the Land and Maritime Silk Roads នៅទីក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន

- បានចូលរួមប្រជុំស្តីអំពីការរៀបចំអនុស្សរណៈនៃការយោគយល់គ្នានិងផែនការសកម្មភាពរវាងភាគីកម្ពុជា និងភាគីថៃ

- បានប្រជុំដើម្បីរកវិធានការទប់ស្កាត់ និងទប់ទល់តម្លៃធ្លាក់ចុះផលិតផលកសិកម្ម ជាពិសេសដំណាំស្រូវ

- បានបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នឹងឯកសារពង្រាងស្នើសុំចុះកិច្ចសន្យា គំរូកិច្ចសន្យា សារាចរណែនាំ និងរៀបចំការបង្កើតគណៈកម្មាធិការសម្របសម្រួលផលិតកម្មកសិកម្មតាមកិច្ចសន្យា

- បើកវេទិកាប្រជុំចរចាការអនុវត្តន៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា រវាងកសិករ (ភាគីអ្នកផលិត) និងក្រុមហ៊ុន (ភាគីអ្នកទិញ) នៅក្នុងខេត្តបាត់ដំបងបានចំនួន០១លើក ស្តីពីការភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូច ទៅនឹងទីផ្សារតាមរយៈផលិតកម្ម កសិកម្មតាមកិច្ចសន្យា ដែលមានការចូលរួមពីអាជីវករ និងកសិករមកពីសហគមន៍កសិកម្ម

- បានរៀបចំផែនការសកម្មភាពគម្រោងលើកទី៣ ដាក់ជូនសហភាពអឺរ៉ុប (EU) ពាក់ព័ន្ធផលិតកម្មកសិកម្មតាមកិច្ចសន្យា

- បានចូលរួមប្រជុំជាមួយក្រុមហ៊ុនជប៉ុន JAPAN FARM PRODUCTS (Cambodia) Co., Ltd និង SARAYA (Cambodia) Co., Ltd ស្តីពីការគ្រោងធ្វើគម្រោងទាក់ទងវិស័យកសិកម្មក្រោមជំនួយរបស់ ទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិ JICA។

## ៤ ផ្នែកផលិតកម្ម និងបសុព្យាបាល

**៤.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងកំពុងរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្ត និងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

- **ការងារកែលម្អពូជ៖** មន្រ្តីជំនាញបានចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព មានការលូតលាស់ឆាប់រហ័សធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់ ក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយដៃគូពាក់ព័ន្ធ។
- **ការងារឡជីវឧស្ម័ន៖** ដោយមានការអភិវឌ្ឍផ្នែកចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននិងកំពុងអនុវត្តយ៉ាងសកម្មដែលមកទល់ពេលនេះខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់សម្រេចបាន ១ ១០៤ឡ និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបាន ២៥០ឡ។
- **ចំណីសត្វ៖**បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។
- **ការងារដំណាំចំណីសត្វ៖** តាមបណ្តាខេត្តមួយចំនួនបានធ្វើសួនដំណាំចំណីសត្វ ធ្វើការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការបន្តជាមួយគម្រោង CIAT។

### ៤.២ ការងារបសុព្យាបាល

- លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖

រាជធានី-ខេត្តចំនួន ២២បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ២៩ ៩៧៣លើកនៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយក្រុមអន្តរាគមន៍របស់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលសរុប ៤០ករណី ក្នុងនោះមានបទល្មើស ០១ករណីដោយបានកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន ៦៦០,៨គីឡូក្រាម និងជាកពិន័យជាទឹកប្រាក់បានចំនួន ៣២លាន ៩សែនរៀល ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនជ្រូករស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញ ដើម្បីការពារការឆ្លងរាលដាលនៃជំងឺជ្រូកត្រចៀកខៀវមកពីខេត្តជិតខាង។

- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យជាប្រចាំលើទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តាខេត្ត-រាជធានី រហូតមកទល់ពេលនេះសត្តឃាតដ្ឋានទទួលបានគោលការណ៍អនុវត្តចំនួន ១៤៨កន្លែង និងចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស។
- ស្ថិតិសត្តឃាតដ្ឋានដែលទទួលបានការអនុញ្ញាតនៅទូទាំងប្រទេសសរុបចំនួន ១៤៨កន្លែង ហើយចំនួនសត្វដែលបានពិឃាតក្នុងសត្តឃាតដ្ឋានទាំងនោះ ដូចមានតារាងខាងក្រោម៖

| ល.រ | ឈ្មោះរាជធានី-ខេត្ត | ចំនួនសត្តឃាតដ្ឋាន | | ចំនួនសត្វពិឃាត | | | |
|---|---|---|---|---|---|---|---|
| | | សត្តឃាតដ្ឋានស្របច្បាប់ | ពិឃាតប្រមូលផ្តុំ/ពិឃាតតាមផ្ទះ | គោ (ក្បាល) | ក្របី (ក្បាល) | ជ្រូក (ក្បាល) | មាន់ (ក្បាល) |
| ១ | ភ្នំពេញ | ១២ | | ១២ ០៨៦ | | ២៣០ ៣៤៦ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | កណ្តាល | ២៣ | | | | | |
| ៣ | កំពង់ស្ពឺ | ១១ | | ៥ ១០៤ | | ២ ៨២១ | |
| ៤ | ព្រៃវែង | ១២ | | ២៦២ | ៤ | ៣ ៣៤០ | |
| ៥ | ស្វាយរៀង | ៨ | ១ | ១ ៥១២ | ៤៧ | ១២ ៩១៧ | |
| ៦ | កំពង់ឆ្នាំង | ១០ | | | | | |
| ៧ | ពោធិ៍សាត់ | ៦ | | ២៥៥ | ១៦ | ១ ៩៣៥ | |
| ៨ | បាត់ដំបង | ១៤ | | ១០ ៩៤៨ | ២៧៤ | ៤៧ ១៦៦ | |
| ៩ | បន្ទាយមានជ័យ | ១១ | | | | | |
| ១០ | សៀមរាប | ៧ | | | | | |
| ១១ | កំពង់ធំ | ៦ | | ៥ ១៤៨ | ៦៤១ | ២៩ ៦៨៩ | |
| ១២ | ព្រះសីហនុ | ៣ | | | | | |
| ១៣ | កែប | ១ | | | | | |
| ១៤ | កំពត | ៥ | | ២ ៣២៥ | | ១៩ ៥៨៧ | ៩ ៩៤០ |
| ១៥ | កោះកុង | ៣ | | | | | |
| ១៦ | ក្រចេះ | ៥ | | ៤ ៣៥៧ | | ២៥ ៥០៩ | |
| ១៧ | ស្ទឹងត្រែង | ១ | | | | | |
| ១៨ | រតនគិរី | ៣ | | | | | |
| ១៩ | មណ្ឌលគិរី | ២ | | | | | |
| ២០ | ប៉ៃលិន | ៣ | | | | | |
| ២១ | ឧត្តរមានជ័យ | ១ | | | | | |
| ២២ | តាកែវ | ១ | ១៨ | ៣ ៧៣៩ | | ២៨ ៦០១ | |
| ២៣ | កំពង់ចាម | | ១០ | ៣ ៦៤៦ | | ២១ ៦៤៧ | ២១ ១៥៧ |
| ២៤ | ត្បូងឃ្មុំ | | ៧ | | | | |
| ២៥ | ព្រះវិហារ | ៣ | | | | | |
| សរុប | | ១៤៨ | ៤២ | ៤៩ ៣៨២ | ៩៨២ | ៤២៣ ៥៥៨ | ៣១ ០៩៧ |

- **ការងារនីតិកម្មនិងវិវាទ៖** បន្ទាប់ពីច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ក្រសួងបានរៀបចំបោះពុម្ពនិងធ្វើសិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈឲ្យបានទូលំទូលាយ និងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់តាមអាទិភាព។

**៤.៣ ការងារស្រាវជ្រាវ៖**

- **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ឬនៅតាមសត្តឃាតដ្ឋាន ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺជាពិសេសមេរោគជំងឺផ្តាសាយបក្សី។ ក្នុងខែកញ្ញា នេះពិនិត្យវត្ថុវិភាគសរុបបានចំនួន ៥ ៨៦០វិភាគ។
- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន ១១១ក្បាល ក្នុងនោះគោបាចំនួន ១ក្បាល គោប្រាម៉ាន់កាត់ចំនួន ៦ក្បាល គោជំទង់ចំនួន ៣៨ក្បាល គោបៅដោះចំនួន ២៧ក្បាល គោកំផែងសែនចំនួន ៣៩ក្បាល គោកើតថ្មីចំនួន ៣ក្បាល និងគោលក់ចំនួន ៤ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុបចំនួន ៣២៤ក្បាល ក្នុងនោះជ្រូកបាចំនួន ៦ក្បាល ជ្រូកមេចំនួន ៦៧ក្បាល កូនជ្រូកចំនួន ៩០ក្បាល មេជ្រូកត្រៀមលក់ចំនួន ១០៥ក្បាល ជ្រូកថែមថ្មីចំនួន ៥ក្បាល កូនជ្រូកលក់ចំនួន

៤៣៤ក្បាល និងជ្រូកបម្រុងចំនួន ១៤ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតីនិងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

**៤.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ។

## ៥ ផ្នែកព្រៃឈើ

### ៥.១ ការងារព្រៃឈើ

- ទទួលថវិកាពីមូលនិធិអភិវឌ្ឍព្រៃឈើជាតិចំនួន ១០២ ៣៨៦ ០០០៛ សម្រាប់ដំណើរការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ២០១៦ លើខណ្ឌរដ្ឋបាលព្រៃឈើចំនួន ០៤ (ព្រៃវែង ពោធិ៍សាត់ មណ្ឌលគិរី និងកំពត)
- រៀបចំកិច្ចសន្យាជាមួយខណ្ឌរដ្ឋបាលព្រៃឈើគោលដៅទាំង ០៤ (ព្រៃវែង ពោធិ៍សាត់ មណ្ឌលគិរី និងកំពត)
- បានបញ្ចប់ការប្រមូលទិន្នន័យរូបភាពផ្កាយរណបប្រភេទ LANDSAT8 ដើម្បីធ្វើការវាយតម្លៃធនធានគម្របដីព្រៃឈើ ឆ្នាំ២០១៦
- បានបញ្ចប់ការវាយតម្លៃធនធានគម្របដីព្រៃឈើឆ្នាំ២០១៤ និងបម្រែបម្រួលធនធានគម្របដីព្រៃឈើឆ្នាំ ២០០៦-២០១០ និង២០១៤ ព្រមទាំងបានរៀបចំសៀវភៅធនធានគម្របដីព្រៃឈើឆ្នាំ២០១៤
- បានសហការជាមួយជំនាញការ FFPRI ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ប្រភេទគម្របព្រៃឈើ និងគម្របដីនៅទីវាលចំនួន ១២០ចំណុច ដើម្បីគាំទ្រការកសាងផែនទីធនធានគម្របព្រៃឈើឆ្នាំ២០១៥-២០១៦ នៅ ខេត្តមណ្ឌលគិរី រតនគិរី កោះកុង ពោធិ៍សាត់ និងបាត់ដំបង និងធ្វើការវាយតម្លៃធនធានគម្របព្រៃឈើឆ្នាំ២០១៦ សម្រេចបាន២០%
- បានសហការជាមួយគម្រោង AFoCo រៀបចំវគ្គបណ្តុះបណ្តាលការកសាងសមត្ថភាពក្នុងការវាយតម្លៃធនធានព្រៃឈើ និងបង្កើនការយល់ដឹងដល់សហគមន៍មូលដ្ឋានស្តីពីផលប៉ះពាល់អវិជ្ជមានពីការប្រែប្រួលអាកាសធាតុ
- សហការជាមួយគម្រោង ITTO រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃកម្រិតជឿជាក់លើបម្រែបម្រួលចំណាត់ថ្នាក់ប្រើប្រាស់ធនធានគម្របដីព្រៃឈើ
- បានពិនិត្យ និងកែសម្រួលឯកសារកម្រិតបំភាយយោងការបញ្ចេញឧស្ម័នកាបូនិកពីការបាត់បង់ និងរេចរឹលព្រៃឈើដាក់ជូនសន្និសីទនៃរដ្ឋភាគីលើកទី២២នៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ក្រោមកិច្ចគាំទ្របច្ចេកទេសពីជំនាញការ JICA-CAM-REDD និងFAO
- បានដាំកូនឈើជាចម្ការនៅលើផ្ទៃដីទំហំ ១៥០ហិកតា នៅស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើអូរបឹងរូងខេត្តកំពង់ធំ ផ្ទៃដីទំហំ ១៥០ហិកតា នៅស្ថានីយផ្សព្វផ្សាយ និងស្តារទីជម្រាលក្បាលឆាយ ខេត្តព្រះសីហនុ និងបានដាំកូនឈើ ជាចម្ការនៅលើផ្ទៃដីទំហំ ៥០ហ.ត នៅស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើយុនរាម ខេត្តសៀមរាប
- បានដាំដុះកូនឈើរាយប៉ាយតាមដងផ្លូវ និងលើខ្នងប្រឡាយបានប្រវែង ៦ ០២៧ម៉ែត្រ
- បានបណ្តុះកូនឈើគ្រប់ប្រភេទបានចំនួន ១ ៦៤១ ៧៦២ ដើម
- ចែកកូនឈើជូនប្រជាពលរដ្ឋបានចំនួន ១ ២៩៥ ៣៤៩ដើម
- បានអភិវឌ្ឍធនធានសេនេទិចប្រភេទឈើផ្ចៀក តាមរយៈការបង្កើតចម្ការពូជនៅលើផ្ទៃដីទំហំ១០ហ.តនៅស្ថានីយផ្សព្វផ្សាយ និងស្តារទីជម្រាលក្បាលឆាយ ខេត្តព្រះសីហនុ
- បានដាំកូនគ្រញូងចំនួន ២០០០ដើម បញ្ចូលទៅក្នុងតំបន់ប្រភពគ្រាប់ពូជឈើគ្រញូងនៅ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

### ៥.២ ការងារអភិរក្សសត្វព្រៃ

- បានចុះប្រមូលសំណាកសត្វកណ្តុរចំនួន ៣ ៤៣៣សំណាក ស្មើនឹង ៣២១ក្បាល នៅក្នុងខេត្តមណ្ឌលគិរី ខេត្តកំពង់ធំ និងខេត្តព្រះវិហារ ដើម្បីធ្វើការវិភាគរកមេរោគនិងជំងឺ
- បានចុះប្រមូលសំណាកសរុបចំនួន ១ ៣៦៧សំណាក ពីសត្វប្រចៀវ-ជ្រឹងចំនួន ៤៨៦ក្បាល នៅខេត្តកណ្តាល ខេត្តបាត់ដំបង និងខេត្តកំពត ដើម្បីយកទៅធ្វើការវិភាគរកមេរោគដែលមាននៅក្នុងខ្លួនសត្វប្រចៀវ-ជ្រឹង

- បានចុះប្រមូលសំណាកលាមកដំរីស្រស់នៅតំបន់ជួរភ្នំក្រវាញ នៃខេត្តកោះកុងចំនួន ០៥លើក ដោយទទួលបាន សំណាកលាមកដំរីសរុបចំនួន ៣៧១សំណាក ក្នុងនោះលាមកស្រស់មានចំនួន ២០៦សំណាក លាមកស្រស់បង្គួរមានចំនួន១៣០សំណាក និងលាមកក្រៀមមានចំនួន៣៥សំណាក

- បានរៀបចំអារហារដ្ឋានត្មាតចំនួន ០៨លើក នៅនៅតំបន់លិចទឹកទន្លេមេគង្គក្នុងខេត្តក្រចេះ និង ស្ទឹងត្រែង ដោយរាប់ឃើញត្មាតចំនួន១៧ក្បាល

- បានការពារសម្បុកត្រដក់តូចចំនួន ១១សម្បុក ត្រយ៉ងចង្កំកសចំនួន ២១សម្បុក រំពេទន្លេចំនួន ១៧សម្បុក និងសម្បុកត្មាតប្រផេះចំនួន ០១នៅតំបន់លិចទឹកទន្លេមេគង្គ ក្នុងខេត្តក្រចេះនិងស្ទឹងត្រែង

- បានចុះសម្របសម្រួលជាមួយប្រជាពលរដ្ឋចំនួន ៥០គ្រួសារ ដែលទទួលរងការបំផ្លាញដំណាំពីសត្វដំរីព្រៃ និងបានកត់ត្រាការខូចខាតចេកអស់ ១៦គុម្ព ស្វាយចន្ទី ខ្នុរ ធុរេន និងដំឡូងមី ក្នុងស្រុកកំពង់សីលា ខេត្តព្រះសីហនុ

- បានផ្តល់ឧបករណ៍ និងសម្ភារសម្រាប់បង្អើលដំរី ដល់ប្រជាពលរដ្ឋនៅភូមិព្រែកស្មាច់ ឃុំកោះស្តេច ស្រុកគីរីសាគរ ភូមិព្រែកស្វាយ ឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង ដែលមានចំនួនគ្រួសារសរុប ៦គ្រួសារ រួមមានកាំជ្រួច ២០០ដើម ភ្លើងញាក់ ១០គ្រឿង ខ្សែក្រណាត់បន្ទះ និងប្រេងខ្មៅបង្ការពេលដំរីចូលមកបំផ្លាញ

- បានរៀបចំកិច្ចប្រជុំការអប់រំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលជាមួយនិងប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាចំនួន ៤៩លើក ដែលមានអ្នកចូលរួមចំនួនសរុប ២ ៣៥៨នាក់ ដោយផ្តោតទៅលើការការពារនិងអភិរក្ស សត្វស្លាបនៅតាមដងទន្លេមេគង្គក្នុងខេត្តក្រចេះ និងការអភិរក្សសត្វក្តាន់ ក្នុងឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ និងឃុំវឌ្ឍនៈ ស្រុកសំបូរ ខេត្តក្រចេះ

- បានចុះផ្សព្វផ្សាយស្តីពីសារសំខាន់និងការជួញដូរសត្វព្រៃចំនួន ០៤លើកនៅក្នុងខេត្តមណ្ឌលគិរី រតនគិរី ព្រះវិហារ និងស្ទឹងត្រែងដែលមានអ្នកចូលរួមសរុបចំនួន ២៤០នាក់

- បានបោះពុម្ពអាវយឺតចំនួន ៤០០ និងផ្ទាំងផុស្ទ័រស្តីពីការការជួញដូរសត្វព្រៃចំនួន ៤០០ផ្ទាំងដើម្បីផ្សព្វផ្សាយ

- បានចុះពង្រឹងការគ្រប់គ្រប់តំបន់ព្រៃការពារ អន្តរាគមន៍បន្ទាន់ និងការដោះអន្ទាក់បានចំនួន ១៣លើក ក្នុងនោះ តំបន់អន្លង់ព្រីង ០១លើក តំបន់អភិរក្សសត្វខ្សឹបកំពង់ធំ ០១លើក ព្រៃការពារជួរភ្នំក្រវាញភាគកណ្តាល ០១លើក ព្រៃការពារមណ្ឌលគិរី ០២លើក ព្រៃការពារព្រះវិហារ ០២លើក ព្រៃការពារសីមា ០១លើក តំបន់ព្រៃតំបន់អភិរក្សសត្វក្រៀលបឹងព្រែកល្ពៅ ០១លើក តំបន់អភិរក្សសត្វក្រៀលអាងត្រពាំងថ្ម ០១លើក តំបន់ស្រាវជ្រាវវដ្តទឹក ០១លើក សហគមន៍ព្រៃឈើសង្ឃរុក្ខាវ័ន្តឧត្តរមានជ័យ ០១លើក និងសហគមន៍ព្រៃឈើព្រៃគ្រឡាច ក្នុងខេត្តបាត់ដំបង ០១លើក។

### ៥.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជសត្វក្អាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ខែកញ្ញា ឆ្នាំ២០១៦នេះ ការងារនៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាគឺ៖ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន ១ ៥៧៦ក្បាល សត្វកើតថ្មីចំនួន ៦៥ក្បាល ព្យាបាលសត្វព្រៃរបួសនិងឈឺចំនួន ១ ០១២ក្បាល ដោះលែងទៅព្រៃធម្មជាតិវិញចំនួន ១ ២៨១ក្បាល ជួសជុលផ្លូវលំសំបុកមាន់ផ្លូវក្រាលក្រួសក្រហមបានទំហំប្រវែង ២៤ ៤២៧ ម៉ែត្រ កាប់ឆ្ការអនាម័យព្រៃបានទំហំ ២៨,៥ហ.ត សាងសង់និងជួសជុលទ្រុងសត្វឬសំណង់ផ្សេងៗបានចំនួន ៦ ៦៨៩ម$^{2}$ ។ សត្វព្រៃសរុបចំនួន ១ ៤៥៦ក្បាល (បក្សី ៥០ប្រភេទ ថនិកសត្វ ៤៥ប្រភេទ និងល្មូន ១៣ប្រភេទ)

- ក្រុមល្បាតសហគមន៍ចំនួន ២៨នាក់ បន្តការងារល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៥ គឺនៅអារ៉ែងឆាយរាប តំបន់ស្តារក្រពើស្ទឹងជាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់) ហើយបានដោះលែងក្រពើចំនួន ៧ក្បាល។

### ៥.៤ ការដាំដើមឈើ

- បានដាំកូនឈើជាចម្ការនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួនបីកន្លែងសម្រេចបានលទ្ធផលលើផ្ទៃដីទំហំ ៣៥០ហ.ត

- បានថែទាំចម្ការឈើពីឆ្នាំទី១ដល់ ឆ្នាំទី៥ មានផ្ទៃដីសរុបទំហំ ២ ១៩៣ហ.ត ស្ថិតនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើទូទាំងប្រទេស

- បានបណ្តុះកូនឈើគ្រប់ប្រភេទបានចំនួន ១ ៦៤១ ៧៦២ដើម

- បានចែកកូនឈើជូនប្រជាពលរដ្ឋបានចំនួន ១ ២៩៥ ៣៤៩ដើម

- ពិធីវុក្ខទិវាថ្នាក់ជាតិថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៦ បានប្រារព្ធឡើងក្រោមអធិបតីភាព **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** តំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តមសីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាស្ថិតនៅចំណុចគ១ ភូមិធម្មជាតិ សម្តេចតេជោ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារដាំផ្ទៃដីទំហំ ១២ហិកតា ( គ្រញូង ធ្នង់ បេង កកោះ និងច្រេស ) និងមានអ្នក ចូលរួមសរុបចំនួន ៧ ០០០នាក់

- ពិធីវុក្ខទិវាឆ្នាំ២០១៦ ថ្នាក់ខេត្តបានរៀបចំនៅតាមបណ្តាខេត្ត រាជធានីដោយខណ្ឌរដ្ឋបាលព្រៃឈើមូលដ្ឋានចំនួន ២៥ ទទួលបានលទ្ធផលដូចខាងក្រោមៈ

- ផ្ទៃដីដាំដុះក្នុងពិធីវុក្ខទិវាមានទំហំ ៩០ហ.ត៦៧
- ដាំដុះកូនឈើវាយប៉ាយតាមដងផ្លូវ និងលើខ្នងប្រឡាយបានប្រវែង ៦ ០២៧ម៉ែត្រ
- ចែកជូនកូនឈើដល់ប្រជាពលរដ្ឋ ៥៨ ១៤០ដើម
- ចំនួនអ្នកចូលរួម ២៣ ៧៧២នាក់

- បានអភិវឌ្ឍធនធានសេនេទិចប្រភេទឈើផ្ចឹក តាមរយៈការបង្កើតចម្ការពូជនៅលើផ្ទៃដី ទំហំ១០ហ.ត នៅស្ថានីយផ្សព្វផ្សាយ និងស្តារទីជម្រាលក្បាលឆាយ ខេត្តព្រះសីហនុ និងដាំកូនគ្រញូងចំនួន ២ ០០០ដើម បញ្ចូលទៅក្នុងតំបន់ប្រភពគ្រាប់ពូជឈើគ្រញូងនៅស្រុក បន្ទាយស្រី ខេត្តសៀមរាម

- ក្រុមហ៊ុនស៊ីងបាយអូចេក (ខេមបូឌា)ខូ អិល ធី ឌី ជាដៃគូបានដាំកូនឈើជាចម្ការនៅលើផ្ទៃដីទំហំ ៤៥០ហ.ត នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ បឹងចារ

- បានជីកប្រឡាយទប់ស្កាត់ និងការពារតំបន់ប្រភពគ្រាប់ពូជឈើគ្រញូង ស្ថិតក្នុងស្រុកបន្ទាយស្រី ខេត្តសៀមរាប បានប្រវែង ៤០០ម៉ែត្រ។

### ៥.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ចុះពិនិត្យទីតាំងរោងម៉ាស៊ីនអារ-កែច្នៃឈើតាមលក្ខណៈបច្ចេកទេសមានក្រុមហ៊ុនចំនួន ១២ និងសុំបន្តសុពលភាពមានក្រុមហ៊ុនចំនួន ១៦

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលរានទេវតាទៅបរទេសចំនួន ៤ក្រុមហ៊ុន ដែលមានបរិមាណសរុប ២ ៩៥០ម$^{៣}$ និងជ័រទឹកចំនួន ៦០ តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលឈើចំនួន ៤ក្រុមហ៊ុ ប្រភេទឈើ CHANFUTA TALYWOOD UMBILA និងឈើ MDF មានបរិមាណសរុប ៦៦៤ម$^{៣}$ ។

### ៥.៦ ការងារចំណូលព្រៃឈើ

- សម្រាប់រយៈពេល៩ខែដើមឆ្នាំ២០១៦នេះចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើសរុបចំនួន ១២ ១៤០ ៥៥៩ ៨៨៥ រៀល និងចំណូលពីសេវាសាធារណៈចំនួន ៣ ៩៦៩ ៣៤០ ៤១៣រៀល និង១០៨ ៨៧៥,៦៨ដុល្លារអាមេរិក។

### ៥.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់រយៈពេល៩ខែដើមឆ្នាំ២០១៦នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន ១ ១៦៦ករណី ដោយបញ្ជូនទៅតុលាការចំនួន ៨៧៣ករណី និងពិន័យអន្តរការណ៍ចំនួន ២៩៣ករណី

- ឃាត់ខ្លួនជនល្មើសនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន ៦ ៦៨២ម$^{៣}$ ឈើអារចំនួន ៥ ៤០៧ម$^{៣}$ ឈើក្រាក់គ្រញូងចំនួន ៤២ម$^{៣}$ និង៥២៦គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន ១ ១៧២ក្បាល និង៣ ០៦៥គ.ក្រ អនុផលព្រៃឈើ និងសម្ភារផ្សេងៗមួយចំនួនទៀតដកហូតរណារយន្តបានចំនួន ២៤៩គ្រឿង និងសំណុំរឿងបទល្មើសកាប់រានដីព្រៃចំនួន ១៨២ករណី មានផ្ទៃដីព្រៃឈើដែលកាប់រានចំនួន ៤ ៧២០ហ.ត ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី

- បានចុះពង្រឹងការអនុវត្តច្បាប់ចំនួន ១៥លើក នៅក្នុងខេត្តកំពង់ចាមចំនួន ០១លើក ត្បូងឃ្មុំចំនួន ០៣លើក ក្រចេះចំនួន ០៣លើក មណ្ឌលគិរីចំនួន ០២លើក រតនគិរីចំនួន ០២លើក ស្ទឹងត្រែងចំនួន ០២លើក កំពង់ធំចំនួន ០១លើក និងព្រះវិហារចំនួន ០១លើក



6

- បានចុះតាមដាន ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ការងារពាក់ព័ន្ធការកាប់រានដីព្រៃចំនួន ៤៨ករណី ក្នុងនោះខេត្តកំពង់ឆ្នាំង ចំនួន ១១ករណី ខេត្តពោធិ៍សាត់ចំនួន ០៨ករណី ខេត្តបាត់ដំបងចំនួន ០១ករណី ខេត្តព្រះវិហារចំនួន ០៣ករណី ខេត្តកំពង់ធំចំនួន ០៣ករណី ខេត្តក្រចេះចំនួន ០៦ករណី និងខេត្តស្ទឹងត្រែងចំនួន ១៦ករណី

- អធិការដ្ឋានរដ្ឋបាលព្រៃឈើទាំង៤ បានសហការជាប់ជាប្រចាំជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ក្នុងការចុះទប់ស្កាត់បង្ក្រាប់បទល្មើសព្រៃឈើ សត្វព្រៃ និងការលួចកាប់ព្រៃឈើយកដីធ្វើជាកម្មសិទ្ធិ

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប។

## ៦ ផ្នែកជលផល

### ៦.១ អាជីវកម្មនេសាទ

#### ៦.១.១ នេសាទទឹកសាប

- ដាយត្រី ការធ្វើអាជីវកម្មត្រូវបានផ្អាកសកម្មភាពចាប់ពីខែមេសារហូតដល់ខែកញ្ញា។ រីឯលទ្ធផលដែលអនុវត្តបានក្នុងរយៈពេល៣ខែដើមឆ្នាំ២០១៦នេះចំនួន ១ ០៥០តោន ស្មើនឹង ៨,៧៥% នៃផែនការ ១២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ២៣៥តោន

- នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន ២៦ ៧០០តោន សរុបរយៈពេល៩ខែបានចំនួន ២០៦ ០០០តោន ស្មើនឹង ៥៩,៨៨% នៃផែនការ ៣៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ១៤ ៣៥០តោន

- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន ១៨ ១០០តោន សរុបរយៈពេល៩ខែបានចំនួន ៧១ ៦០០តោន ស្មើនឹង ៤៩,៧២% នៃផែនការ ១៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ១៥ ៧៥៥ តោន។

#### ៦.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ១០ ៦០០តោន សរុបរយៈពេល៩ខែបានចំនួន ៨៥ ៤០០តោន ស្មើនឹង ៧៧,៦៤% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៧ ៤០០តោន។

### ៦.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន ២៥ ៥០០តោន សរុបរយៈពេល៩ខែបានចំនួន ១៤៣ ៣៥០តោន ស្មើនឹង ៨២,៩៦% នៃផែនការ ១៧២ ៨០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៣១ ២៥០ តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន ៣៥ ០០០ក្បាល សរុបរយៈពេល៩ខែបានចំនួន ២៣៧ ០០០ក្បាល ស្មើនឹង ៩៤,៨០% នៃផែនការ ២៥០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៥១ ៥០០ក្បាល

- ការភ្ញាស់កូនត្រីពូជ អនុវត្តបានចំនួនប្រមាណ ២២ ០០០ ០០០កូន សរុបរយៈពេល៩ខែបានចំនួន ១៤៩ ០០០ ០០០កូន ស្មើនឹង ៨២,៧៨% នៃផែនការ ១៨០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួនប្រមាណ ៤ ០០០ ០០០កូន

- បានរៀបចំទិវាមច្ឆជាតិ ១ កក្កដា ឆ្នាំ២០១៦ នៅខេត្តកំពង់ស្ពឺក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

### ៦.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាប អនុវត្តបានចំនួន ៦ ០០០តោន សរុបរយៈពេល៩ខែបានចំនួន ៤៦ ៧០០តោន ស្មើនឹង ៥៦,៩៥% នៃផែនការ ៨២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ១ ៧០០តោន

- ផលនេសាទសមុទ្រ អនុវត្តបានចំនួន ៨០០តោន សរុបរយៈពេល៩ខែបានចំនួន ៨ ៣២៥តោន ស្មើនឹង ១០៤,០៦% នៃផែនការ ៨ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៥២៥តោន



៤1

- ការផលិតទឹកត្រី អនុវត្តបានចំនួន ៣ ០០០ ០០០លីត្រ សរុបរយៈពេល៩ខែបានចំនួន ៤៤ ៥០០ ០០០លីត្រ ស្មើនឹង ៨៩,០០% នៃផែនការ ៥០ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ៥ ៥០០ ០០០លីត្រ។

### ៦.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ អនុវត្តបានចំនួន ៥០០តោន សរុបរយៈពេល៩ខែបានចំនួន ៦ ៨០០តោន ស្មើនឹង ៤៥,៣៣% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ៣០០តោន

- ផលនេសាទកែច្នៃ អនុវត្តបានចំនួន ២០០តោន សរុបរយៈពេល៩ខែបានចំនួន ៣ ៧០០តោន ស្មើនឹង ៧៤,០០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ គ្មានការកើនឡើង។

### ៦.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- សម្រាប់រយៈពេល៩ខែដើមឆ្នាំ២០១៦នេះ សំណុំរឿងបទល្មើសជលផលមានចំនួន ២ ៥៤១ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២ ៤០៤ករណី និងសមុទ្រចំនួន ១៣៧ករណី។ ដោយឡែកសម្រាប់ខែកញ្ញានេះ បទល្មើសជលផលមានចំនួន ៤៦២ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ៤៣៥ករណី និងសមុទ្រចំនួន ២៧ករណី

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង ២២៦ ៤២០ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន ៣ ៦៥៥មាត់ បង្គោល/ចម្រឹងចំនួន ១២៨ ៥១៨ដើម ឧបករណ៍ឆក់ត្រីចំនួន ៣១គ្រឿង និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន ១២ ៤៧៩គ.ក្រ

- ចាប់ពីដើមឆ្នាំ២០១៦នេះ បានផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន ១២៩វគ្គ ដោយមានអ្នកចូលរួមចំនួន ៥ ៣៦១នាក់ ក្នុងនោះស្ត្រីចំនួន ៨៩០នាក់។ ដោយឡែកក្នុងខែកញ្ញា ឆ្នាំ២០១៦នេះ អនុវត្តបាន ១៥វគ្គ ដោយមានអ្នកចូលរួមចំនួន ៦២៥នាក់

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យ និងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព និងចាត់វិធានការទប់ស្កាត់និងបង្ក្រាបបទល្មើសជលផលក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត។

### ៦.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផល សម្រាប់ខែកញ្ញា ឆ្នាំ២០១៦ ចំនួន ២៧២ ២៨៣ ៨០០រៀល សរុបរយៈពេល ៩ខែបានចំនួន ១ ៥៨៥ ៦៨២ ៤៨០រៀល ស្មើនឹង ៥២,៨៦% នៃផែនការ ៣ ០០០ ០០០ ០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ១ ២៣០ ៩០៩ ២៩៥រៀល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- វិទ្យាស្ថានបានរៀបចំពិព័រណ៍ស្រូវ-អង្ករនៃពូជស្រូវល្អៗ និងទើបបញ្ចេញថ្មីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងចូលរួមជាវាគ្មិនក្នុងវេទិកាស្រូវ-អង្ករលើកទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ហើយសម្តេចនាយករដ្ឋមន្ត្រី ក៏បានផ្តល់អនុសាសន៍ដល់វិទ្យាស្ថានបន្តធ្វើការផលិតគ្រាប់ពូជគ្រឹះ ដើម្បីរក្សាភាពសុទ្ធរបស់ពូជ។ វិទ្យាស្ថានបានចូលរួមរៀបចំពិធីបុណ្យរំឭកខួបទី៣០ នៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) ក្រោមអធិបតីភាព **ឯកឧត្តម យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទវិទ្យាស្ថានចំនួន៤រូបបានទទួលមេដាយការងារពី IRRI។ ទន្ទឹមនឹងនោះក៏បានចូលរួមតាំងពិព័រណ៍ក្នុងទិវាប្រយុទ្ធប្រឆាំងនឹងឱនភាពដី នៅខេត្តតាកែវ

- វិទ្យាស្ថានបានប្រជុំ និងចូលរួមប្រជុំ និងសិក្ខាសាលាផ្សេងៗក្នុងប្រទេសចំនួន ៧២លើក និងក្រៅប្រទេសចំនួន ៨លើក ហើយបានទទួលជួបភ្ញៀវនៅវិទ្យាស្ថានចំនួន៣៥លើក ដែលមានភ្ញៀវសរុបចំនួន ១០០នាក់។ វិទ្យាស្ថានបានលើកផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ២០១៧ ដោយទទួលបានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ

- បានបន្តការអភិរក្សពូជដំណាំចំនួន ៣៣ប្រភេទដែលរួមមានស្រូវចំនួន ៦ ៦៤៥បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ៣២ប្រភេទសរុបចំនួន ១ ២៥៥បញ្ជីក/សំណាក សរុបទាំងអស់មានចំនួន ៧ ៩០០បញ្ជីក/សំណាក បានវាយតម្លៃ

និងកំណត់លក្ខណៈសំណាកម្ទេសនិងត្រសក់ស្រូវបានចំនួន ៤៩និង ៤១សំណាករៀងគ្នា និងបានធ្វើយុវកម្មស្រូវចំនួន ២ ១៦០បញ្ជីក/សំណាក

- បានធ្វើពិសោធន៍ជ្រើសរើសស្រឡាយស្រូវនិងដំណាំផ្សេងៗ ចំនួន ១ ០១៧ស្រឡាយដើម្បីជ្រើសរើសៈ ១-ស្រឡាយស្រូវដែលមានអាយុកាលខ្លីជាង ១០០ថ្ងៃ ២-ស្រឡាយស្រូវធន់ទ្រាំនឹងរាំងស្ងួត ៣-ស្រឡាយស្រូវធន់ទ្រាំនឹងទឹកជំនន់ ៤-ស្រឡាយស្រូវធន់ទ្រាំនឹងមមាចត្នោត ៥-ស្រឡាយស្រូវដែលមានតម្រូវការទឹកតិច ៦-ស្រឡាយស្រូវក្រអូប ៧-ស្រឡាយស្រូវមានទិន្នផលខ្ពស់ ៨-ស្រឡាយស្រូវដែលធន់នឹងការជ្រុះគ្រាប់ ៩-ស្រឡាយស្រូវដែលធន់នឹងកម្តៅ និង ១០-ស្រឡាយពោត សណ្តែក ល្ង ប៉េងប៉ោះ ឪឡឹក ម្ទេស និងដំឡូងផ្វាធន់នឹងកម្តៅ មានទិន្នផល និងគុណភាពល្អ

- វិទ្យាស្ថានបានកំពុងធ្វើពិសោធន៍ចំនួន ៧៥ប្រភេទ នៅ៦០៧កន្លែង ស្វែងរកប្រភេទដំណាំ និងការប្រើប្រាស់ជីសមស្រប សម្រាប់ធ្វើការដាំដុះក្នុងរដូវប្រាំងក្រោយពីដាំដុះដំណាំស្រូវរដូវវស្សារួច

- បានធ្វើពិសោធន៍ចំនួន ២៩ប្រភេទនៅ១០៦កន្លែង ដែលក្នុងនោះរួមមានពិសោធន៍លើការកំណត់សំណើមដីប្រសិទ្ធភាពការប្រើប្រាស់ជី ឥទ្ធិពលវិធីសាស្ត្រដាំដុះ និងឥទ្ធិពលគុណភាពទឹកលើដំណាំ មានចំនួន ៧ប្រភេទ សរុបចំនួន ៧៣កន្លែង ពិសោធន៍លើការដាំដុះពូជស្រូវមានតម្លៃខ្ពស់ ការរៀបចំដី ការប្រើប្រាស់ម៉ាស៊ីនដាំគ្រាប់ធញ្ញជាតិ ការប្រើប្រាស់ម៉ាស៊ីនដាំគ្រាប់ពូជស្រូវស្ងួត និងការងារក្រោយពេលប្រមូលផល មានចំនួន ៨ប្រភេទ សរុបចំនួន ៨កន្លែង ព្រមទាំងពិសោធន៍លើពូជស្រូវធន់នឹងសត្វល្អិតចង្រៃ រុក្ខជាតិចង្រៃ ជំងឺលើដំណាំ វិធានការគ្រប់គ្រងសមាសភាពចង្រៃ និងថ្នាំកសិកម្ម មានចំនួន ១៤ប្រភេទ សរុបចំនួន ២៥កន្លែង

- បានផ្តល់បទសម្ភាសន៍ក្នុងកម្មវិធីដៃគូកសិករ របស់វិទ្យុអេហ្វអឹម ១០២នៃមណ្ឌលព័ត៌មានស្ត្រីក្រោមប្រធានបទពូជធន់ ដោយមានការចូលរួមសាកសួរតាមទូរស័ព្ទពីអ្នកស្តាប់ បានចំនួន ០១លើក និងបានទទួលជួបសម្ភាសន៍ជាមួយទូរទស្សន៍ CNC ចំនួន០១លើក អំពីការបញ្ចេញពូជស្រូវថ្មីៗរបស់វិទ្យាស្ថាន និងផ្តល់អនុសាសន៍ជូនដល់កសិករសម្រាប់ចាប់ផ្តើមដាំដុះដំណាំស្រូវនាដើមរដូវវស្សាឆ្នាំនេះ។ ថ្នាក់ដឹកនាំការិយាល័យចំនួន២រូប បានចូលរួមបង្រៀនថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម

- បានដឹកនាំនិស្សិតស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របានចំនួន ០៨នាក់ ដែលក្នុងនោះ ០៤នាក់មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ០១នាក់មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង០៣នាក់មកពីសាលាជាតិកសិកម្មព្រែកលៀប។ វិទ្យាស្ថានបានបើកវគ្គបណ្តុះបណ្តាលបានចំនួន ០៥វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ១៣០នាក់ និងបានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្រៅប្រទេសចំនួន ១៥លើក ដែលមានថ្នាក់ដឹកនាំ និងមន្ត្រីវិទ្យាស្ថានចូលរួមចំនួន ២៣នាក់។ មន្ត្រី និយោជិតសរុបចំនួន៧រូបបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតនៅក្រៅប្រទេស

- **គេហទំព័រ** http://www.cardi.org.kh និង http://crkb.org.kh: ក្នុងរយៈពេលមួយឆមាស ឆ្នាំ២០១៦ នេះ មានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ៥៣៣ ៥៣៩នាក់ ហើយគិតជាមធ្យមមានប្រមាណ ២ ២២៣នាក់/ថ្ងៃ កើនលើសមធ្យមប្រចាំឆ្នាំ២០១៥ចំនួន ១ ០២០នាក់/ថ្ងៃ។

## ៨ ផ្នែកនីតិកម្មកសិកម្ម

### ៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន ១៧៦ក្រុមហ៊ុន សរុបចំនួន ២ ២៦០មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ១៦០ក្រុមហ៊ុន ត្រូវជា២២៣ករណី
- ចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្មចំនួន ២៧ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មចំនួន ៣១ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៥ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ០៦ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

- ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជិកាចំនួន ៨៤ក្រុមហ៊ុន សរុបចំនួន ៥៤៣សំណាក។

### ៨.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម ជូនដល់មន្ទីរកសិកម្មខេត្តមណ្ឌលគិរី ក្រចេះ ត្បូងឃ្មុំ ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ រតនគិរី ស្ទឹងត្រែង ព្រះវិហារ ព្រៃវែង និងខេត្តកំពង់ចាម សរុបចំនួន ៥៥៤នាក់

- បានបើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈនិងធ្វើជាគ្រូឧទ្ទេសនាមដល់អាជីវករ ជាអ្នកលក់ដុំលក់រាយសម្ភារកសិកម្មនៅខេត្តកំពង់ធំ សៀមរាប និងខេត្តកំពង់ចាមដែលមានអ្នកចូលរួមចំនួន ៣២៧នាក់

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការលើកកម្ពស់ការយល់ដឹងស្តីពី "បទដ្ឋានគិតយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម" ទៅដល់មន្ទីរកសិកម្មរាជធានី-ខេត្ត ដែលមានអ្នកចូលរួមចំនួន ១៤៩នាក់ និងតាមរយៈថវិកាកម្មវិធីនៅកំពង់ធំ និងខេត្តសៀមរាប។

### ៨.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យការនាំចូលរបស់ក្រុមហ៊ុនដែលបានប្រកាសប្រតិវេទន៍អំពីការនាំចូល និងស្នើសុំចុះបញ្ជិកាឃ្លាំងសន្និធិជីកសិកម្ម និងថ្នាំកសិកម្មចំនួន ៧១ក្រុមហ៊ុន

- ពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៩៣ ៤០០ ០០០រៀល ពីក្រុមហ៊ុនចំនួន ១៤ និងដេប៉ូចំនួន ២៣។

## ៩ ផ្នែករដ្ឋបាល

- ក្នុងនព្វមាសនេះ ទទួលលិខិតពីក្រសួង-ស្ថាប័ននានា បានចំនួន ៣ ១៦៥ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣ ១២៩ច្បាប់ និងទទួលពីរាជធានី-ខេត្តចំនួន ១ ១១៧ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៨ ៣២០ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៦១១ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទចំនួន ២៨១ច្បាប់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការ ការរៀបចំពិធីបុណ្យផ្សេងៗ និងការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួង។

## ១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៦ ៦៤៤នាក់ នារីចំនួន ១ ៣៩៦នាក់ ស្មើនឹង ២១% រួមមានៈ
  + អង្គភាពថ្នាក់កណ្តាលចំនួន ៤ ០៤២នាក់ ក្នុងនោះនារីចំនួន ៨១៣នាក់ ស្មើនឹង ២០%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន ២ ៦០២នាក់ ក្នុងនោះនារីចំនួន ៥៨៣នាក់ ស្មើនឹង ២២%

- តែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ១៤០នាក់ នារីចំនួន ១៣នាក់

- ចេញប្រកាសលុបឈ្មោះមន្ត្រីសុំលាឈប់ពីការងារចេញពីក្របខ័ណ្ឌមានចំនួន ៣៥នាក់ ក្នុងនោះបោះបង់ការងារចំនួន ០៤នាក់ សុំលាឈប់ពីការងារចំនួន ១១នាក់ និងមរណភាពចំនួន ២០នាក់

- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងមានចំនួន ២៣នាក់ ផ្ទេរចូលក្រសួងមានចំនួន ១៧នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន ១០៦នាក់

- បានចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងមន្ត្រីកសិកម្មរាជធានី ខេត្ត លើ៣តំបន់

- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកពីការងារចំនួន ៧៧នាក់ ក្នុងនោះឈប់សម្រាកប្រចាំឆ្នាំចំនួន ៤៩នាក់ (ស្រី ១៤នាក់) ព្យាបាលជំងឺចំនួន ០៨នាក់ និងសម្រាកលំហែមាតុភាពចំនួន ២០នាក់

- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា

- បានចេញប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ១៦០នាក់ (នារីចំនួន ២៧នាក់)

- បានចេញប្រកាសឱ្យមន្ត្រីរាជការ ចូលបម្រើការងារនៅអង្គភាពដើមវិញចំនួន ១១៣នាក់
- បានចេញប្រកាសដាក់មន្ត្រីឱ្យចូលនិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈចំនួន ១៣៤នាក់ (នារីចំនួន ០១នាក់)
- បានចេញប្រកាសស្តីពីការអនុញ្ញាតឱ្យជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាចំនួន ១ ០២៤នាក់
- ចូលរួមវគ្គបណ្តុះបណ្តាលការងាររយៈពេលខ្លីនិងមធ្យមក្នុងនិងក្រៅប្រទេសចំនួន ៣១១នាក់។

## ១១ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានសម្របសម្រួលជាមួយមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិសម្រេចបានជោគជ័យក្នុងការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការលើវិស័យកៅស៊ូកម្ពុជា

- បានសម្របសម្រួលជាមួយក្រសួងកសិកម្មនៃប្រទេសម៉ាឡេស៊ីសម្រេចបាននូវការឯកភាពគ្នាលើអនុស្សរណៈនៃការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការលើបច្ចេកទេសកសិកម្មរវាងប្រទេសទាំងពីរ

- បានសម្របសម្រួលជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដូចជា JVC, IVY, FAO, UNOP, FIDR នឹងឈានទៅសម្រេចបានក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៃការអនុវត្តគម្រោង

- បានសម្របសម្រួលជាមួយលេខាធិការដ្ឋានអាស៊ានដើម្បីរៀបចំសិក្ខាសាលាថ្នាក់តំបន់នៃក្រុមការងារជំនាញបច្ចេកទេសអាស៊ានសម្រាប់រៀបចំគោលនយោបាយព្រៃឈើអន្តរជាតិ ដែលមានសមាជិកចូលរួមមកពីបណ្តាប្រទេសអាស៊ានទាំង១០ ក្នុងការរៀបចំគោលនយោបាយព្រៃឈើអន្តរជាតិ កិច្ចប្រជុំលើកទី១២ នៃក្រុមការងារបច្ចេកទេសអាស៊ាន កិច្ចប្រជុំលើកទី៤ នៃក្រុមប្រឹក្សាស្បៀងបម្រុងសង្គ្រោះបន្ទាន់អាស៊ានបូក៣ ដែលមានសមាជិកចូលរួមមកពីបណ្តាប្រទេសអាស៊ានទាំង១០

- សហការជាមួយអង្គការ GROW ASIA ក្នុងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីភាពជាដៃគូរបស់កម្ពុជាដើម្បីអភិវឌ្ឍន៍កសិកម្មឱ្យមាននិរន្តរភាព

- បានសម្របសម្រួលជាមួយ CDC លើសំណើបញ្ជូនគម្រោង Improvement of Commune Level Agriculture Extension System Rural Development ទៅសាធារណរដ្ឋកូរ៉េ

- ធ្វើសំណើទៅរាជរដ្ឋាភិបាលដើម្បីស្នើសុំសិទ្ធិប្រទានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបង្កើតមជ្ឈមណ្ឌលអាស៊ានសម្រាប់សុខភាពសត្វ និងជំងឺស៊ូណូល

- បានសម្របសម្រួលទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើម្បីផ្តល់គម្រោងផែនការរំកិល ២០១៦-២០១៨ សម្រាប់អនុវត្តផែនការសកម្មភាពមេគង្គ-ជប៉ុន និងយុទ្ធសាស្ត្រក្រុងតូក្យូថ្មី២០១៥ ការផ្តល់យោបល់លើសេចក្តីព្រាង Roadmap for Asia Cooperation Dialogue (ACD) Regional Connectivity សម្រាប់លើកយកទៅអនុម័តនៅក្នុងកិច្ចប្រជុំកំពូល ADC លើកទី២ នៅទីក្រុងបាងកក ប្រទេសថៃ បន្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការ VSO និងសេចក្តីព្រាងអនុស្សរណៈស្តីពីផលិកម្មកសិកម្ម កម្ពុជា-រុស្ស៊ី

- បានសម្របសម្រួលទៅក្រសួងផែនការ សុំផ្តល់យោបល់លើសេចក្តីព្រាងលើការតភ្ជាប់សេដ្ឋកិច្ចរវាងប្រទេសទាំងពីរកម្ពុជា-វៀតណាម

- បានសម្របសម្រួលទៅក្រសួងពាណិជ្ជកម្ម អំពីសំណើសុំផ្តល់យោបល់លើសេចក្តីព្រាងឯកសារគោលគំនិតស្តីពីការតភ្ជាប់អាស៊ានសហរដ្ឋអាមេរិក

- បានស្នើសុំសិទ្ធិប្រទានពីរាជរដ្ឋាភិបាលដើម្បីសុំចុះហត្ថលេខាលើពិធីសាររវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចិត្តាឡីស័កនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការនាំអង្គុរ និងចុងអង្គុរទៅប្រទេសចិន

- បានសម្របសម្រួលចុះ MOU រវាងរដ្ឋបាលព្រៃឈើ និងវិទ្យាស្ថានជាតិធនធានជីវចម្រុះនៃសាធារណរដ្ឋកូរ៉េ ដើម្បីបន្តកិច្ចសហប្រតិបត្តិការលើធនធានជីវចម្រុះនិងព័ត៌មាន

- បានសម្របសម្រួលរាល់កិច្ចការទំនាក់ទំនងក្នុងនិងក្រៅប្រទេសដើម្បីបញ្ជូនមន្ត្រីក្រោមឱវាទក្រសួងបានទៅចូលរួមសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលនានានៅក្រៅប្រទេស

- បានលើកសំណើទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសុំអ្នកជំនាញស្ម័គ្រចិត្តជនជាតិកូរ៉េ World Friend Korea: Advisors Program ១រូប តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ សម្រាប់នាយកដ្ឋានវិស្វកម្មកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

- បានសម្របសម្រួលរាល់កិច្ចការទំនាក់ទំនងក្នុង និងក្រៅប្រទេសដើម្បីជូនថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទក្រសួងបានទៅចូលរួមបេសកកម្ម សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានានៅក្រៅប្រទេស រួមទាំងការទទួលជួបសវនាការរបស់ថ្នាក់ដឹកនាំជាមួយអង្គទូត និងដៃគូអភិវឌ្ឍន៍នានាផងដែរ។

## ១២ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១២.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦ សរុបចំនួន ៦៦៤នាក់ (ស្ត្រី ២៣១នាក់) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាចំនួន ៥០៥នាក់(ស្ត្រី ១៨៣នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន ១៥៩នាក់(ស្ត្រី ៤៨នាក់)។ សាលាបានរៀបចំប្រឡងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររងដោយជោគជ័យ និងចែកសញ្ញាបត្របណ្តោះអាសន្នជូននិស្សិត។ កំពុងទទួលពាក្យចូលរៀនឆ្នាំ២០១៦-២០១៧ និងបានទៅបំពេញទស្សនកិច្ចនៅកោះតៃវ៉ាន់ ដើម្បីសិក្សាអំពីកសិកម្មធម្មជាតិ និងជំរុញកិច្ចសហប្រតិបត្តិការ។ សាលាបានទៅទស្សនកិច្ចនៅប្រទេសថៃដើម្បីសិក្សាអំពីកសិកម្មសិរីរាង្គ ការចិញ្ចឹមគោសាច់ ជលផល និងចុះអនុស្សរណៈយោគយល់គ្នា។ ទន្ទឹមនឹងនេះ សាលាបានបន្តចុះរារាំងការទន្ទ្រានយកដីរបស់សាលាពីប្រជាពលរដ្ឋនៅស្រុកថ្កូង ខេត្តកំពង់ស្ពឺ ដោយសហការជាមួយអភិបាលស្រុកថ្កូង ដើម្បីឈានដល់ការដោះស្រាយឱ្យបានឆាប់ និងបានបន្តការរៀបចំកន្លែងពិសោធន៍ត្រីសម្រាប់បម្រើការសិក្សារបស់និស្សិត ព្រមទាំងសហការជាមួយភាគីចិនក្នុងការសាងសង់ រៀបចំកែលម្អមន្ទីរពិសោធន៍និងហេដ្ឋារចនាសម្ព័ន្ធរបស់សាលា។

### ១២.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥-២០១៦ សរុបមានចំនួន ៩០៨នាក់(ស្ត្រី ៣៧០នាក់) រួមមាន៖

- និស្សិតអាហារូបករណ៍សរុប ៨៥៩នាក់ (ស្ត្រី ៣៥៤នាក់) ក្នុងនោះថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មចំនួន ៤៥៥នាក់(ស្ត្រី ១៧៨នាក់) និងថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មចំនួន ១២៥នាក់(ស្ត្រី ៥១នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃចំនួន ៤៩នាក់ (ស្ត្រី ១៦នាក់) ថ្នាក់បរិញ្ញាបត្រចំនួន ៣៨នាក់(ស្ត្រី ១៥នាក់) និងថ្នាក់បរិញ្ញាបត្ររងចំនួន ១១នាក់ (ស្ត្រី ១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកជំនួយ ក្នុងនោះកំពុងសហការជាមួយអង្គការពេទ្យសត្វគ្មានព្រំដែនដើម្បីរៀបចំមន្ទីរពិសោធន៍សត្វ និងបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍។ សាលាបានសហការជាមួយអង្គការ OISCA បញ្ជូននិស្សិតជំនាញក្សេត្រសាស្ត្រចំនួន ០១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល១ឆ្នាំនៅប្រទេសជប៉ុន ព្រមទាំងជាមួយទីភ្នាក់ងារ KOICA ដើម្បីផ្តល់អាហារូបករណ៍សម្រាប់សាស្ត្រាចារ្យ ០១រូប ទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិត នៅប្រទេសកូរ៉េ បានទទួលជួបតំណាង JICA ពិភាក្សាពីគម្រោងកសិកម្មសរីរាង្គ និងកំពុងសហការរៀបចំគម្រោងស្រាវជ្រាវ បានទទួលតំណាង JICA ពិភាក្សាពីគម្រោងសិក្សាអង្កេតពីភាពរីកចម្រើននៃសហគមន៍កសិកម្មដែលមានទីតាំងនៅជុំវិញខេត្តកំពង់ចាម ព្រមទាំងបានសហការជាមួយ DTRA (Defence Threat Reduction Agency) បើកវគ្គអំពី៖ ប៉ារ៉ាស៊ីតសត្វឆ្លងទៅមនុស្ស អេពីដេមីសាស្ត្រ ជំងឺផ្តាសាយបក្សី ជីវសុវត្ថិភាពដោយផ្តោតលើជំងឺឆ្លងពីសត្វមកមនុស្សនិងពីមនុស្សមកសត្វ និងវគ្គស្តីពីការអភិវឌ្ឍកម្មវិធីថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសត្វនិងវេជ្ជសាស្ត្រសត្វ ដល់និស្សិត និងមន្ត្រីជំនាញ ២០រូប ដែលមកពីបណ្តាខេត្តស្តីពីការអនុវត្តអេពីដេមីសាស្ត្របសុព្យាបាល ជំនាន់ទី៣ និងវគ្គស្តីពីកាកសំណល់រឹង និងរាវ នៅទីសត្តឃាតនិងកសិដ្ឋានចិញ្ចឹមសត្វ។

### ១២.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥ សរុបមានចំនួន ៣ ៩២៤នាក់(ស្ត្រី ១ ១៨៧នាក់) ចែកចេញជា១០ មហាវិទ្យាល័យគឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រ



៤១

ព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងថ្នាក់ក្រោយឧត្តម ដើម្បីបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ ក្នុងខែកញ្ញានេះ និស្សិតទាំងអស់ត្រូវរៀនបញ្ចប់មេរៀន និងបានប្រឡងឆមាសទី២ ឆ្នាំសិក្សា ២០១៥-២០១៦ របស់ខ្លួន រួចរាល់ជាស្ថាពរ ។ ទន្ទឹមនឹងនេះ ដោយសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម សាកលវិទ្យាល័យបាន បើកវគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយកសិកម្ម (Agricultural Extension Advisor) ជូនដល់មន្ត្រីកសិកម្មគ្រប់ខេត្តក្រុងចំនួន ៦០នាក់ បានធ្វើសិក្ខាសាលាអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រសម្រាប់បណ្តុះបណ្តាលជំនាញវិទ្យាសាស្ត្រសត្វនិងវេជ្ជសាស្ត្រសត្វដោយសហការជាមួយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល និងបានធ្វើសិក្ខាសាលា Summer School ស្តីពី From Net to Spoon ជូនដល់និស្សិតដោយសហការជាមួយសាកលវិទ្យាល័យប្រាកនៃប្រទេសឆេក។ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទៅបំពេញបេសកកម្ម និងបានចូលរួមពិធីប្រគល់វិញ្ញាបនបត្របញ្ចប់ការសិក្សារបស់និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្មចំនួន ១០២នាក់ ដែលបានបញ្ចប់កម្មសិក្សារបស់ខ្លួនរយៈពេល១១ខែ ដោយជោគជ័យនៅប្រទេសអ៊ីស្រាអែល ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយជាបង្គួរនៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេស តែតំបន់ខ្លះពុំទាន់មានទឹកគ្រប់គ្រាន់សម្រាប់ការលូតលាស់របស់ដំណាំកសិកម្មពិសេសដំណាំស្រូវ។ រីឯស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ សម្រេចបាន ១០២,៧៦% លឿនជាងឆ្នាំមុន ៥០ ៣០៤ហ.ត (ស្មើនឹង ៥,៥៩%) បើប្រៀបធៀបរយៈពេលដូចគ្នា។ ក្រសួងបានដាក់ចេញជាវិធានការជំរុញការងារបង្កបង្កើនផលស្រូវវស្សាឆ្នាំ២០១៦នេះ ដោយបានណែនាំដល់អង្គភាពក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ឱ្យយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវវស្សាតាមរយៈការផ្តល់អនុសាសន៍ដល់កសិករឱ្យអនុវត្តផលិតកម្មដំណាំស្រូវតាមលក្ខណៈប្រពលវប្បកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ដោយពិចារណាទៅលើយន្តការនិងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងករណីមានគ្រោះរាំងស្ងួត ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។ ទន្ទឹមនឹងនេះ ក៏បានជំរុញចាត់វិធានការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាព ព្រមទាំងជំរុញការជីកស្តារស្រះ ប្រឡាយ អាងស្តុកទឹក រក្សាទឹកទុកបង្ការការខ្វះខាតនៅចុងរដូវ។ ក្នុងកាលៈទេសៈដែលកសិករកំពុងប្រមូលផលស្រូវស្រាលដើមរដូវវស្សានេះក៏មានការបន្ទាបតម្លៃស្រូវនៅលើទីផ្សារដែលធ្វើឱ្យប៉ះពាល់ទៅលើចំណូលរបស់កសិករផងដែរ។ ករណីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការណែនាំទៅដល់អង្គភាពជំនាញ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តដោយត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញពាក់ព័ន្ធដើម្បីជួយរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។ ទោះបីជាមានបញ្ហាលើការធ្លាក់ចុះតម្លៃស្រូវខុសពីឆ្នាំមុនៗក៏ដោយ ក៏រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃនិងប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានអំពាវនាវដល់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ និងដោះស្រាយបញ្ហាទាំងនេះបានទាន់ពេលវេលាហើយទទួលបានការអបអរសាទរពីបងប្អូនប្រជាកសិករយើងនៅទូទាំងប្រទេសផងដែរ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាព ពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ ជាមួយគ្នានេះ ក្រសួងក៏បានរៀបចំជាគណៈកម្មការនិងក្រុមការងារតាមការចាំបាច់ដើម្បីចូលរួមដោះស្រាយឱ្យបានទាន់ពេលវេលាលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ជាពិសេស បន្តសហការអនុវត្តអនុក្រឹត្យលេខ៣៨អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលតួនាទីនិងភារកិច្ចរបស់ក្រសួងបរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពាក់ព័ន្ធនឹងសមត្ថកិច្ចនិងការគ្រប់គ្រងក្នុងក្របខ័ណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល រួមមានការផ្ទេរមុខងាររបស់ខ័ណ្ឌរដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលទៅថ្នាក់ក្រោមជាតិឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដែលក្រសួងបានចេញប្រកាសរួចហើយ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែ

ទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការឆ្នាំ២០១៦នេះ។

## IV- **ទិសដៅអនុវត្តបន្ត**

### **១ ផ្នែកដាំដុះ :**

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវវស្សា និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសសមស្របឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៦ ពិសេសធានាសុវត្ថិភាពនិងសុខមាលភាពសាធារណៈ

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាពសន្សំសំចៃ ដើម្បីកាត់បន្ថយផលប៉ះពាល់បង្កដោយគ្រោះរាំងស្ងួត គ្រោះខ្វះទឹកដែលអាចកើតឡើងនៅចុងរដូវ និងដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ ព្រមទាំងចូលរួមទប់ស្កាត់ការបញ្ចុះតម្លៃកសិផល ពិសេសតម្លៃស្រូវក្នុងពេលប្រមូលផលស្រូវស្រាលដើមរដូវនេះ

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- បន្តណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់សហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយទប់ស្កាត់ការធ្លាក់ចុះតម្លៃស្រូវទាន់ពេលវេលា ចាត់ចែងជាបន្តក្នុងការរៀបចំក្រុមការងារសម្របសម្រួលថ្នាក់តំបន់និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវអង្ករនៅមូលដ្ឋាន ព្រមទាំងកំពុងរៀបចំចាត់មន្ត្រីជំនាញ ដើម្បីត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យនៅតាមច្រកនាំចេញនាំចូលឱ្យបានសមស្របតាមវិធានបច្ចេកទេស និងនីតិវិធីដោយអនុលោមតាមស្មារតីនៃលិខិតលេខ ៩៤២ សជណ.កស ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល។ ដោយឡែក ក្រសួងបន្តចុះពិនិត្យតាមដានការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វផ្សេងៗ និងចាត់ក្រុមអន្តរាគមន៍ចុះទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្តជាប់ជាប្រចាំ

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត់ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចនិងផ្តល់ក្តីសង្ឃឹមអំពីតម្លៃកៅស៊ូនៅលើទីផ្សារដែលអាចនឹងឡើងថ្លៃវិញនៅពេលអនាគត។

### **២ ផ្នែកផលិតកម្មនិងបសុព្យាបាល :**

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺជ្រូកត្រចៀកខៀវ ក៏ដូចជាជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តាខេត្ត-រាជធានី និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ ជាពិសេសការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមតំបន់ដែលខ្សត់ទឹក

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី-ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣ ផ្នែកព្រៃឈើ :**

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើសំខាន់ៗ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង ស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាព រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២ និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

**៤ ផ្នែកជលផល:**

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តតាមដាននិងសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការទប់ស្កាត់បទល្មើសនេសាទ ពិសេសក្នុងរដូវបិទនេសាទឆ្នាំ២០១៦

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងគិតគូរអំពីមធ្យោបាយសង្គ្រោះធនធានមច្ឆជាតិនៅពេលឡើងកម្តៅខ្លាំងបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៦ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិងទាន់ពេលវេលា ការផ្ទេរមុខងារតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ ព្រមទាំងការបញ្ចូលសកម្មភាពយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំ

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេសព្រមទាំងការរៀបចំអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាលតាមគំរូថ្មីដោយអនុលោមតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៩៥ សសរ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥

- បន្តរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា តាមស្មារតីនៃលិខិតលេខ១៣០៣ សជណ.សរ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

- បន្តសហការអនុវត្តអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលតួនាទីនិងភារកិច្ចរបស់ក្រសួងបរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសមត្ថកិច្ចនិងការគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងការគ្រប់គ្រងតំបន់ការពារនិងអភិរក្សព្រៃឈើ ជាពិសេសការផ្ទេរតំបន់ព្រៃ

ការពារ តំបន់អភិរក្សព្រៃឈើចំនួន ១៣កន្លែង និងព្រៃផ្តល់ផលចំនួន ៥កន្លែង ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទៅក្រសួងបរិស្ថានគ្រប់គ្រង និងបានផ្ទេរតំបន់សម្បទានដីសេដ្ឋកិច្ចចំនួន ៧៣កន្លែង ពីក្រសួងបរិស្ថាន ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់គ្រងបន្ត តាមរយៈអនុក្រឹតលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៦

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ គោលការណ៍ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ការសម្រួលភារកិច្ច ក្នុងការបញ្ចូលខ័ណ្ឌរដ្ឋបាលជលផល និងរដ្ឋបាលព្រៃឈើឱ្យស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្ម មានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្ម មានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស ស្តង់ដារ និងការផលិតសម្រាប់ឈានទៅរកការធ្វើសមាហរណកម្មពាណិជ្ជកម្មផលិតផលកសិកម្មក្នុងបរិបទនៃសាកលភាវូបនីយកម្ម៕

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែតុលា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**